J Trust Royal Bank

# ខចែង និង លក្ខខណ្ឌនៃការផ្តល់ប្រាក់កម្ចីទិញរថយន្ត របស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក

មានសុពលភាពចាប់ពីខែ កក្កដា ឆ្នាំ ២០២៣

# មាតិកា


លក្ខខណ្ឌទូទៅ ........ 3

និយមន័យ ........ 3

1. កម្ចី និងការបើកប្រាក់ ........ 4
2. ការប្រាក់ និងកម្រៃសេវា ........ 4
3. ការទូទាត់សង ........ 4
4. ព្រឹត្តិការណ៍នៃការបំពានកាតព្វកិច្ច ........ 4
5. សិទ្ធិរបស់ធនាគារក្នុងករណីមានព្រឹត្តិការណ៍នៃការបំពានកាតព្វកិច្ច ........ 5
6. ការទូទាត់សងមុនកាលកំណត់ និងការលុបចោល ........ 5
7. ការអនុញ្ញាត ឥណពន្ធ និងសំណងការខូចខាត ........ 6
8. ការប្រើប្រាស់កម្ចី ........ 6
9. មរណៈភាពរបស់អ្នកខ្ចី ឬពិការភាពជាអចិន្ត្រៃយ៍ ........ 6
10. ការបង្ហាញព័ត៌មាន ........ 7
11. ការជូនដំណឹង និងទំនាក់ទំនងដោយធនាគារ ........ 7
12. ការណែនាំ និងទំនាក់ទំនងដោយអ្នកខ្ចី ........ 8
13. ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និង ហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ........ 8
14. ច្បាប់គ្រប់គ្រង ការដោះស្រាយវិវាទ និងការកែប្រែខថែងនិងលក្ខខណ្ឌនេះ ........ 9
15. បញ្ញត្តិទូទៅ ........ 9

# លក្ខខណ្ឌទូទៅ

ខចែង និងលក្ខខណ្ឌនៃការផ្តល់កម្ចីទិញរថយន្តរបស់ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ (តទៅហៅកាត់ថា "**ខចែង និងលក្ខខណ្ឌ**") ដោយរាប់បញ្ចូលទាំងលិខិតផ្តល់ឥណទាន (តទៅហៅកាត់ថា "**លិខិតផ្តល់ឥណទាន**") បង្កើតបានជាកិច្ចព្រមព្រៀងឥណទានរវាងធនាគារ និងអ្នកខ្ចី។ តាមរយៈការចុះកិច្ចព្រមព្រៀងឥណទាន ដោយមានការចុះហត្ថលេខាលើលិខិតផ្តល់ឥណទាន អ្នកខ្ចីយល់ព្រមទទួលយកកាតព្វកិច្ចដែលមានចែងក្នុង ខចែង និងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងឥណទាននេះ។

ខចែង និងលក្ខខណ្ឌនេះ ត្រូវអនុវត្តរួមគ្នាជាមួយនឹង ខចែង និងលក្ខខណ្ឌទូទៅរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក ដែលរួមមាន សេវាធនាគារបុគ្គល ព្រមទាំង ខចែង និងលក្ខខណ្ឌនៃផលិតផល និងសេវាកម្មផ្សេងទៀតដែលកំពុងអនុវត្តចំពោះផលិតផល និងសេវាកម្មដែលផ្តល់ជូនអ្នកខ្ចី។ ខចែង និងលក្ខខណ្ឌទាំងនេះ អាចស្នើសុំបាន នៅតាមសាខារបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក។ លើកលែងតែមានការកំណត់ផ្សេងពីនេះ ខចែង និងលក្ខខណ្ឌនេះ ត្រូវមានឧត្តមានុភាព ប្រសិនបើមិនមានសង្គតិភាពរវាង ខចែង និងលក្ខខណ្ឌនេះ ជាមួយនឹង ខចែង និងលក្ខខណ្ឌដទៃទៀតដែលកំពុងអនុវត្តចំពោះអ្នកខ្ចី។

ការផ្តល់កម្ចីនេះ ត្រូវផ្អែកតាមសិទ្ធិជ្រើសរើសទាំងស្រុងរបស់ធនាគារ និងត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញរបស់ធនាគារ។ ការយល់ព្រមទទួលយកលិខិតផ្តល់ឥណទានដោយអ្នកខ្ចី មិនចងកាតព្វកិច្ចចំពោះធនាគារឱ្យត្រូវតែផ្តល់កម្ចីណាមួយទៅឱ្យអ្នកខ្ចីនោះទេ ទោះស្ថិតនៅក្នុងមធ្យោបាយណាមួយក៏ដោយ ប៉ុន្តែ ការយល់ព្រមទទួលយកលិខិតផ្តល់ឥណទាននេះដោយអ្នកខ្ចី បង្កើតឱ្យមានសំណើដែលមាន សុពលភាព និងការយល់ព្រមអនុវត្តតាម ខចែង និងលក្ខខណ្ឌទាំងនេះដោយអ្នកខ្ចី។ ធនាគារ រក្សាសិទ្ធិគ្រប់យ៉ាងក្នុងការ៖ (១) កាត់បន្ថយ ឬ លុបចោលកម្ចីនេះទាំងអស់ (ឬ ចំណែកណាមួយ) គ្រប់ពេលវេលា និង/ឬ (២) តម្រូវឱ្យទូទាត់សងប្រាក់ទាំងអស់មកវិញ រួមទាំងការប្រាក់បង្គរ និងការប្រាក់ពិន័យ ប្រសិនបើមានព្រឹត្តិការណ៍នៃការបំពានកាតព្វកិច្ចលើកិច្ចព្រមព្រៀង (ដូចមានបញ្ជាក់នៅក្នុងប្រការ ៤ ខាងក្រោម) បានកើតមានឡើង ឬអ្នកខ្ចីបានបំពានលើកាតព្វកិច្ចណាមួយរបស់ខ្លួន ដូចមានចែងនៅក្នុង ខចែង និងលក្ខខណ្ឌផ្សេងទៀតដែលកំពុងអនុវត្តចំពោះអ្នកខ្ចី។

អ្នកខ្ចី ធានា និងអះអាងចំពោះធនាគារថា នៅគ្រប់ពេលវេលា រាល់ព័ត៌មានទាំងអស់ដែលអ្នកខ្ចីផ្តល់ឱ្យធនាគារ គឺជាការពិត និងត្រឹមត្រូវ ក្នុងគ្រប់ទិដ្ឋភាពទាំងអស់ ហើយអ្នកខ្ចី ត្រូវបង្ហាញរាល់ព័ត៌មានសំខាន់ៗទាំងឡាយដែលទាក់ទងទៅនឹងទ្រព្យសកម្ម ឬស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន ក៏ដូចជា ព័ត៌មានដែលអាចប៉ះពាល់ជាអវិជ្ជមានចំពោះលទ្ធភាពក្នុងការបំពេញកាតព្វកិច្ចរបស់អ្នកខ្ចី ដូចមានចែងនៅក្នុង ខចែង និងលក្ខខណ្ឌនេះ។

# និយមន័យ

និយមន័យដែលមានចែងដូចខាងក្រោមនេះ មានអានុភាពអនុវត្តចំពោះ ខ ចែង និងលក្ខខណ្ឌនេះទាំងមូលលើកលែងតែមានការចែងផ្សេងពីនេះ៖

"**ធនាគារ**" មានន័យថា **ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់** ម.ក ឬក៏ សិទ្ធិវន្ត ឬសន្តតិជនណាមួយរបស់ធនាគារ។

"**កម្ចី**" មានន័យថា កម្ចីទិញរថយន្ត ដែលធនាគារផ្តល់ទៅឱ្យអ្នកខ្ចី។

"**អ្នកខ្ចី**" មានន័យថា បុគ្គលដែលបានចុះហត្ថលេខាលើទម្រង់ពាក្យស្នើសុំខ្ចី។

## 1. កម្ចី និងការបើកប្រាក់

1.1 អ្នកខ្ចី អាចដកយកប្រាក់កម្ចីបានតែម្តងប៉ុណ្ណោះ បន្ទាប់ពីពេលដែលធនាគារបានយល់ព្រមលើលិខិតផ្តល់ឥណទាន។

1.2 សេចក្តីសម្រេចរបស់ធនាគារទាក់ទងនឹងរយៈពេលខ្ចី និងចំនួនប្រាក់កម្ចី គឺជាសេចក្តីសម្រេចចុងក្រោយ និងចងកាតព្វកិច្ចចំពោះអ្នកខ្ចី បើទោះបីជាមានសំណើរបស់អ្នកខ្ចី នៅក្នុងពាក្យស្នើសុំ កំណត់យ៉ាងណាក៏ដោយ។

1.3 អាស្រ័យទៅលើប្រភេទអតិថិជន អ្នកខ្ចីត្រូវតែបើក និងត្រូវរក្សាគណនីប្រាក់បៀវត្សរ៍ ឬគណនីប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិក (តទៅហៅថា "**គណនី**") នៅធនាគារសម្រាប់គោលបំណងនៃកម្ចីនេះ។ កម្ចីនេះ ត្រូវបានផ្តល់ឱ្យជាប្រាក់ដុល្លារអាមេរិកទៅក្នុងគណនី។

## 2. ការប្រាក់ និងកម្រៃសេវា

2.1 អត្រាការប្រាក់ ត្រូវគណនា តាមមូលដ្ឋានប្រចាំឆ្នាំនៃប្រតិទិន (ប្រចាំឆ្នាំ) ហើយ ក្នុងមួយឆ្នាំ ត្រូវមានរយៈពេល ៣៦០ ។

2.2 អត្រាការប្រាក់នេះ ត្រូវបង្គរជារៀងរាល់ថ្ងៃ ដោយគណនាផ្អែកទៅតាមការថយចុះនៃសមតុល្យ។

2.3 នៅគ្រប់ពេលវេលា ធនាគារ អាចកែប្រែវិធីគណនា ចំនួនដងនៃការសង និងលក្ខខណ្ឌទូទាត់សងណាមួយមានជាអាទិ៍ អត្រាការប្រាក់ កម្រៃសេវា និងសោហ៊ុយផ្សេងៗដោយត្រូវជូនដំណឹងជាមុនទៅអ្នកខ្ចីតាមរយៈមធ្យោបាយទំនាក់ទំនងនានារបស់ ធនាគារ។

2.4 អ្នកខ្ចី ទទួលស្គាល់ និងយល់ព្រមថា ប្រសិនបើវិធីគណនាអត្រាការប្រាក់ដែលធនាគារបានប្រើ ធ្វើឱ្យមានសំណល់សមតុល្យដែលត្រូវសង នៅដំណាក់កាលចុងក្រោយ នោះសំណល់នេះនឹងក្លាយជាផ្នែកមួយនៃប្រាក់ដែលត្រូវសងនាដំណាក់កាលចុងក្រោយហើយត្រូវបង់ជាមួយគ្នានឹងប្រាក់ដែលត្រូវសងនាដំណាក់កាលចុងក្រោយនោះផងដែរ។

## 3. ការទូទាត់សង

3.1 បន្ទាប់ពីមានការទាមទារលើកទីមួយដោយធនាគារ អ្នកខ្ចីត្រូវទូទាត់សងធនាគារ នូវចំនួនដែលដល់កាលកំណត់ត្រូវសង បូករួមនឹងរាល់កំណើនការប្រាក់ និងរាល់កម្រៃសេវាដែលអាចមានចំពោះកម្ចីនោះ។ ការទូទាត់សងនេះ ត្រូវធ្វើឡើងជាប្រាក់ដុល្លារអាមេរិក។

3.2 ប្រាក់ដើម និងការប្រាក់នៃកម្ចីនេះ ត្រូវទូទាត់សងជាដំណាក់កាលដែលមានទឹកប្រាក់ចំនួនស្មើៗគ្នាជារៀងរាល់ខែ (តទៅហៅថា "**ប្រាក់សំណងប្រចាំខែ**") ដែលត្រូវចាប់ផ្តើមអនុវត្ត ១ខែ បន្ទាប់ពីថ្ងៃដែលបានបើកយកប្រាក់តាមរយៈ ការកាត់កងចេញពីគណនីរបស់អ្នកខ្ចី រហូតដល់កម្ចីនោះត្រូវបានទូទាត់សងគ្រប់ចំនួនវិញ។

3.3 ក្នុងករណីដែលមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីធនាគារ នៅគ្រប់ពេលវេលា ធនាគារ អាចអនុញ្ញាតឱ្យអ្នកខ្ចីធ្វើការទូទាត់សងប្រាក់ក្នុងចំនួនណាមួយផ្សេង ក្រៅពីចំនួននៃប្រាក់សំណងប្រចាំខែ។

## 4. ព្រឹត្តិការណ៍នៃការបំពានកាតព្វកិច្ច

ព្រឹត្តិការណ៍នីមួយៗដែលត្រូវបានរៀបរាប់ដូចខាងក្រោម ត្រូវបានចាត់ទុកថាជាព្រឹត្តិការណ៍នៃការបំពានកាតព្វកិច្ចៈ

4.1 **ការមិនបានទូទាត់សង៖** អ្នកខ្ចី ខកខានក្នុងការទូទាត់សងប្រាក់ឱ្យបានគ្រប់ចំនួនដែលបានដល់កាលកំណត់ត្រូវសង ឬដែលត្រូវសងទៅឱ្យធនាគារទៅតាមកាលកំណត់។

4.2 **ការបំពានកាតព្វកិច្ច៖** អ្នកខ្ចី បានបំពានកាតព្វកិច្ចណាមួយរបស់ខ្លួន ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងឥណទាននេះ។

4.3 **ការផ្តល់ព័ត៌មានមិនពិត៖** រាល់អំណះអំណាង ឬព័ត៌មានដែលអ្នកខ្ចីបានផ្តល់ទៅឱ្យធនាគារ (ទោះបីជាដោយផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរ) គឺខុសពីការពិត ឬមិនត្រឹមត្រូវ ឬអាចនាំឱ្យមានការយល់ច្រឡំទៅលើទិដ្ឋភាពសំខាន់ណាមួយ។

4.4 **ភាពផ្ទុយច្បាប់៖** កម្ចីនេះ ត្រូវបានយកទៅប្រើប្រាស់ខុសគោលដៅ ឬមិនស្របច្បាប់ ឬ ការផ្តល់កម្ចី ឬក៏ការបន្តផ្តល់កម្ចីនេះ បណ្តាលឱ្យធនាគារបំពានលើច្បាប់ណាមួយនៃព្រះរាជាណាចក្រកម្ពុជា។

4.5 អ្នកខ្ចី ទទួលមរណៈភាព ក្ស័យធន ឬទទួលស្គាល់ថាខ្លួនគ្មានលទ្ធភាពក្នុងការទូទាត់សងបំណុលណាមួយដែលមានជាមួយម្ចាស់បំណុលរបស់ខ្លួន។

4.6 ដីកា អស្សាមិករណ៍ ការរឹបអូស ឬការអនុវត្តសិទ្ធិអំណាចណាមួយ ដែលប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកខ្ចី។

## 5. សិទ្ធិរបស់ធនាគារក្នុងករណីមានព្រឹត្តិការណ៍នៃការបំពានកាតព្វកិច្ច

នៅពេលមានព្រឹត្តិការណ៍នៃការបំពានកាតព្វកិច្ចណាមួយកើតឡើង អ្នកខ្ចី យល់ព្រម និងអនុញ្ញាតឱ្យ ធនាគារ អាចចាត់វិធានការណាមួយ ឬវិធានការទាំងអស់ ដូចខាងក្រោម៖

5.1 ប្រកាសថាដល់កាលកំណត់ត្រូវសង និងត្រូវតែសង និងទាមទារឱ្យទូទាត់សងនូវចំនួនទឹកប្រាក់ដែលនៅសល់បូករួមនឹងការប្រាក់ដែលបង្គរ និងកម្រៃសេវា ហើយប្រាក់នេះ ត្រូវក្លាយជាប្រាក់ដែលដល់កាលកំណត់សងភ្លាមៗ។

5.2 ចាត់វិធានការណាមួយ ឬធ្វើសកម្មភាពគ្រប់បែបយ៉ាង ដើម្បីប្រមូលមកវិញនូវចំនួនទឹកប្រាក់ណាមួយដែលអ្នកខ្ចីនៅជំពាក់ធនាគារ មានជាអាទិ៍ ផ្តើមនីតិវិធីតាមច្បាប់ ឬដាក់បណ្តឹងនានាដែលធនាគារយល់ថាសមស្រប ។

5.3 បង្កកប្រតិបត្តិការនៃគណនី និង/ឬគណនីផ្សេងទៀតរបស់អ្នកខ្ចីដែលមានជាមួយធនាគារ និងកាត់យកឥណទានដែលនៅមានសល់ក្នុងគណនីនោះ ដើម្បីទូទាត់សងបង្គ្រប់នូវចំនួនដែលអ្នកខ្ចីនៅជំពាក់ធនាគារ ដោយមិនជូនដំណឹងជាមុន ឡើយ។ ប្រសិនបើរូបិយប័ណ្ណក្នុងគណនីនោះ មិនមែនជាប្រាក់ដុល្លារអាមេរិក ធនាគារមានសិទ្ធិប្តូររូបិយប័ណ្ណនោះទៅជារូបិយប័ណ្ណដុល្លារអាមេរិក តាមអត្រាការប្រាក់ដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ននៅក្នុងធនាគារ។

## 6. ការទូទាត់សងមុនកាលកំណត់ និងការលុបចោល

6.1 អ្នកខ្ចី អាចស្នើសុំទូទាត់សងកម្ចីមុនកាលកំណត់ ឬលុបកម្ចីនោះចោល (ឬប្រាក់ដែលនៅសេសសល់ទាំងអស់) ដោយដាក់សំណើជាលាយលក្ខណ៍អក្សរជូនធនាគារ។ រាល់ចំនួនដែលសងមុនកាលកំណត់ ឬលុបចោល ត្រូវធ្វើឡើងឱ្យបានគ្រប់ចំនួន បូករួមទាំងការប្រាក់ដែលបង្គរ ឬកម្រៃសេវា ជាប្រាក់ដុល្លារ អាមេរិក ត្រឹមថ្ងៃដែលស្នើសុំសងមុនកាលកំណត់នោះ។ ធនាគារ រក្សាសិទ្ធិក្នុងការយល់ព្រម ឬបដិសេធចំពោះការសុំ

សងកម្ចីមុនកាលកំណត់ ឬការលុបចោលកម្ចីទាំងនោះ។

6.2 ធនាគារ រក្សាសិទ្ធិកែប្រែកម្រៃសេវានេះ គ្រប់ពេលវេលា ដោយគ្រាន់តែជូនដំណឹងជាមុន ចំនួន 30 ថ្ងៃ។

## 7. ការអនុញ្ញាត ឥណពន្ធ និងសំណងការខូចខាត

7.1 ធនាគារ ត្រូវបានអនុញ្ញាតឱ្យកាត់យកប្រាក់ចេញពីក្នុងគណនី ឬគណនីណាមួយរបស់អ្នកខ្ចីដែលមានជាមួយធនាគារ ដើម្បីទូទាត់សងប្រាក់ណាមួយដែលដល់កាលកំណត់ត្រូវសង ទៅឱ្យធនាគារ

7.2 អ្នកខ្ចី សន្យាទូទាត់សងសំណងការខូចខាតនានាដែលកើតមានចំពោះធនាគារ ដូចជា ថ្លៃ ចំណាយ ការខាតបង់ និងការខូចខាតផ្សេងៗ (រួមទាំងកម្រៃសេវាមេធាវី និងសេវាផ្នែកច្បាប់ផ្សេងទៀត) ដែលធនាគារត្រូវទទួលរង ដោយសារតែអ្នកខ្ចីខកខានក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះ។

7.3 រាល់ប្រាក់សំណងដែលអ្នកខ្ចីត្រូវទូទាត់សងទៅឱ្យធនាគារ មិនត្រូវជាប់ពាក់ព័ន្ធនឹងការកាត់ទុក ការទាមទារ ពន្ធអាករ ពន្ធកាត់ទុក ឬជាប់លក្ខខណ្ឌក្នុងទម្រង់ណាមួយឡើយ លើកលែងតែច្បាប់តម្រូវឱ្យអ្នកខ្ចីបង់ចំពោះការកាត់កង ការទាមទារ ពន្ធអាករ ពន្ធកាត់ទុក ឬ លក្ខខណ្ឌ ដែលនៅក្នុងករណីនេះ ដោយចំនួនសរុបដែលអ្នកខ្ចីត្រូវបង់ ត្រូវតែបង្កើនឱ្យដល់ចំនួនមួយដែលចាំបាច់ ដើម្បីធានាថាធនាគារទទួលបានប្រាក់ដុលសរុបទាំងអស់នៃការកាត់កង ការទាមទារ ពន្ធអាករ ពន្ធកាត់ទុក ឬលក្ខខណ្ឌនោះ ដែលស្មើនឹងប្រាក់ដែលធនាគារត្រូវទទួលបាន ដោយគ្មានការកាត់កង ការទាមទារ ពន្ធអាករ ពន្ធកាត់ទុក ឬលក្ខខណ្ឌនោះ។

## 8. ការប្រើប្រាស់កម្ចី

8.1 ក្នុងអំឡុងពេលដែលកម្ចីនៅមានអត្ថិភាព អ្នកខ្ចីយល់ព្រមប្រើប្រាស់កម្ចីនេះ ស្របតាមគោលបំណងដែលបានបញ្ជាក់នៅក្នុងពាក្យស្នើសុំរបស់អ្នកខ្ចី និងយល់ព្រមបង្ហាញរាល់ព័ត៌មានដែលពាក់ព័ន្ធនឹងការប្រែប្រួល/ផ្លាស់ប្តូរសំខាន់ៗ ក្នុងពេលប្រើប្រាស់កម្ចីនេះ ឬក៏តាមការតម្រូវរបស់ធនាគារ។

8.2 អ្នកខ្ចី ត្រូវប្រើប្រាស់កម្ចីក្នុងគោលបំណងដែលស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ នៅគ្រប់ពេលវេលា ធនាគារ អាចស្នើឱ្យអ្នកខ្ចីផ្តល់ព័ត៌មានដែលពាក់ព័ន្ធនឹងការប្រើប្រាស់កម្ចីនេះ ឬក៏អាចធ្វើការស៊ើបអង្កេតណាមួយលើគោលបំណងនៃកម្ចីនេះ។

## 9. មរណៈភាពរបស់អ្នកខ្ចី ឬពិការភាពជាអចិន្ត្រៃយ៍

អ្នកខ្ចី ទទួលស្គាល់ និងយល់ព្រមថា ប្រសិនបើអ្នកខ្ចីទទួលមរណៈភាពមុនពេលដែលកម្ចីត្រូវបានសងគ្រប់ចំនួន ឬក៏អ្នកខ្ចីអសមត្ថភាពក្នុងការបំពេញការងាររបស់ខ្លួន ដោយសារមូលហេតុណាមួយ នោះកាតព្វកិច្ចក្នុងការសងបំណុលរបស់អ្នកខ្ចី ត្រូវធ្លាក់ទៅលើទាយាទ ឬអ្នកទទួលដែលស្របច្បាប់ ឬបុគ្គលដែលច្បាប់អនុញ្ញាត ឬអាចត្រូវកាត់កងចេញពីទ្រព្យសម្បត្តិរបស់អ្នកខ្ចី ទោះបីជាទ្រព្យនោះស្ថិតនៅកន្លែងណា ឬក៏ក្រោមការគ្រប់គ្រងរបស់បុគ្គលណាមួយក៏ដោយ។ អ្នកខ្ចីយល់ព្រមថា បុគ្គលទាំងនោះនឹងទទួលបានការជូនដំណឹងអំពីលក្ខខណ្ឌនេះ និងយល់ព្រមតាមការរៀបចំនេះភ្លាម បន្ទាប់ពីធនាគារយល់ព្រមផ្តល់កម្ចីនេះ។ ធនាគារ មិនទទួលខុសត្រូវចំពោះសកម្មភាពណាមួយដែលពាក់ព័ន្ធដល់បុគ្គលទាំងនោះ ឬទ្រព្យសម្បត្តិរបស់អ្នកខ្ចី ក្នុងការទូទាត់សងកម្ចីឱ្យបានពេញលេញឡើយ។

## 10. ការបង្ហាញព័ត៌មាន

ធនាគារ អាចបង្ហាញព័ត៌មានណាមួយដែលពាក់ព័ន្ធនឹងអ្នកខ្ចី គណនីរបស់អ្នកខ្ចី កិច្ចព្រមព្រៀងឥណទាន ឬក៏ប្រតិបត្តិការណាមួយដែលស្ថិតនៅក្រោម ឬពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងឥណទាននេះ ឬប្រតិបត្តិការណាមួយផ្សេងទៀតរបស់ធនាគារជាមួយនឹងអ្នកខ្ចីដែលធនាគារយល់ឃើញថាសមស្របទៅឱ្យ៖

(i) ទីស្នាក់ការកណ្តាល សាខា បុត្រសម្ព័ន្ធ ស្ថាប័នដែលមានសម្ព័ន្ធភាព ឬក៏មានការពាក់ព័ន្ធនឹងធនាគារ

(ii) បុគ្គលណាម្នាក់ (រួមមានជាអាទិ៍ស្ថាប័នត្រួតពិនិត្យ មន្ត្រីអនុវត្តច្បាប់ និយ័តករ តុលាការ ឬសាលាជម្រះក្តី) ដែលតម្រូវឱ្យបង្ហាញព័ត៌មាន ដោយ

a. ច្បាប់ជាធរមាន ឬ

b. បទបញ្ជា ការស្នើសុំ ឬលក្ខខណ្ឌតម្រូវណាមួយ (ទោះបីជាមាន ឬគ្មានអានុភាពនៃច្បាប់ក្តី) ដោយរដ្ឋាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតនៃប្រទេសណាមួយ

(iii) សវនករ ឬ ទីប្រឹក្សារបស់ធនាគារដែលមានកាតព្វកិច្ចរក្សាការសម្ងាត់ចំពោះធនាគារ

(iv) ភ្នាក់ងារ ឬ តតិយជន ដែលជាអ្នកផ្តល់សេវាកម្មឱ្យធនាគារ ដែលមានកាតព្វកិច្ចរក្សាការសម្ងាត់

(v) តតិយជនដែលជាអ្នកផ្តល់កិច្ចធានា ឬជំនួយណាមួយផ្នែកឥណទាន (ប្រសិនបើមាន)

(vi) បុគ្គលណាម្នាក់ដែលធនាគារអាចនឹងចុះកិច្ចព្រមព្រៀងដើម្បីធ្វើអនុប្បទាន ប្រគល់សិទ្ធិ ចូលរួម ឬក៏កិច្ចព្រមព្រៀងផ្សេងទៀតដែលពាក់ព័ន្ធនឹងកម្ចីនេះ និង

(vii) ម្ចាស់បំណុលណាម្នាក់របស់អ្នកខ្ចី ឬតតិយជនណាមួយដែលធនាគារបានពិភាក្សាជាមួយ អំពីការរៀបចំឡើង វិញ ឬការអនុវត្តដោយបង្ខំចំពោះបំណុលដែលអ្នកខ្ចីនៅជំពាក់ធនាគារ ក្នុងករណីមានការបំពានកាតព្វកិច្ច ដូចមានចែងក្នុងកិច្ចព្រមព្រៀងឥណទាន។

## 11. ការជូនដំណឹង និងទំនាក់ទំនងដោយធនាគារ

11.1 អ្នកខ្ចី ឯកភាពចំពោះមធ្យោបាយទំនាក់ទំនងតាមរយៈលិខិតតាមប្រៃសណីយ៍ សារជាអក្សរ ទូរសារ សារទូរលេខ សារតាមប្រព័ន្ធអេឡិចត្រូនិច ឬតាមមធ្យោបាយអេឡិចត្រូនិចផ្សេងៗទៀត ដែលប្រើដោយធនាគារ។ ការជូនដំណឹង ឬការទាក់ទងដែលផ្ញើចេញដោយធនាគារទៅកាន់អ្នកខ្ចី តាមរយៈលិខិតប្រៃសណីយ៍ សារជាអក្សរ សារទូរលេខ សារតាមប្រព័ន្ធអេឡិចត្រូនិច ឬតាមរយៈមធ្យោបាយអេឡិចត្រូនិចផ្សេងៗទៀត ដោយប្រើព័ត៌មានលម្អិតដែលអ្នកខ្ចីផ្តល់ឱ្យ ត្រូវបានចាត់ទុកថាបានទទួលដោយអ្នកខ្ចី។

11.2 អ្នកខ្ចី យល់ព្រមថា រាល់ការណែនាំ ការជូនដំណឹង ការយល់ព្រម ឬទំនាក់ទំនងណាមួយពីសំណាក់អ្នកខ្ចីផ្តល់ទៅកាន់ធនាគារ ត្រូវចងភ្ជាប់កាតព្វកិច្ចចំពោះអ្នកខ្ចី។ អ្នកខ្ចី យល់ព្រមផងដែរថា តាមរយៈទូរស័ព្ទ ឬទទួលទូរស័ព្ទ ដែលហៅចេញពីធនាគារ ឬពីតតិយជនដែលជាតំណាងស្របច្បាប់របស់ធនាគារ នោះធនាគារ ឬតតិយជនដែលជាតំណាងស្របច្បាប់របស់ធនាគារ អាចធ្វើការថតសម្លេងរបស់អ្នកខ្ចីក្នុងពេលពិភាក្សាតាមរយៈទូរស័ព្ទនោះ តាមឆន្ទានុសិទ្ធិរបស់ធនាគារ។ អ្នកខ្ចី យល់ព្រមទៀតថា ខ្សែអាត់ ឬសម្លេងថតនៃទំនាក់ទំនងនេះ អាចត្រូវបានធនាគារ ឬតតិយជនណាមួយយកទៅប្រើប្រាស់សម្រាប់គោលបំណងណាមួយ រួមទាំង អាចយកធ្វើជាភស្តុតាងនៅក្នុងបណ្តឹងនានា នីតិវិធីតុលាការ និង រដ្ឋបាល។ អ្នកខ្ចី យល់ព្រមថា ធនាគារអាចគិតកម្រៃ និងសោហ៊ុយចំណាយផ្សេងៗដែលទាក់ទងទៅនឹងប្រតិបត្តិការណាមួយដែលអ្នកខ្ចីណែនាំតាមរយៈទូរស័ព្ទ។

## 12. ការណែនាំ និងទំនាក់ទំនងដោយអ្នកខ្ចី

12.1 អ្នកខ្ចីអនុញ្ញាតឱ្យធនាគារធ្វើសកម្មភាពដែលធនាគារយល់ឃើញថាសមស្រប តាមការណែនាំរបស់អ្នកខ្ចីទៅកាន់ធនាគារ។ គ្រប់ពេលវេលា អ្នកខ្ចី អាចជូនដំណឹង ឬទាក់ទងទៅកាន់ធនាគារអំពីការណែនាំរបស់ខ្លួន តាមរយៈលិខិតប្រៃសណីយ៍ អ៊ីម៉ែល ទូរស័ព្ទ ទូរលេខ ឬទូរសារ។ ធនាគារ អាច (តែមិនមែនជាកាតព្វកិច្ចទេ) តម្រូវឱ្យរៀបចំ ឬធ្វើការណែនាំនោះ តាមទម្រង់ណាមួយជាក់លាក់ ឬតម្រូវឱ្យធ្វើការណែនាំនោះ ជាលាយល័ក្ខណ៍អក្សរ ឬ តាមទម្រង់ណាមួយផ្សេងពីនេះ មុនពេលធនាគារអនុវត្តតាមការណែនាំនោះ។

12.2 ទោះជាយ៉ាងណាក៏ដោយ ធនាគាររក្សាសិទ្ធិក្នុងការបដិសេធ ឬ យល់ព្រមនឹងការណែនាំនោះ តាមដែលធនាគារយល់ថាសមស្រប។ ប្រសិនបើធនាគារមិនទទួលយកការណែនាំ តាមរយៈលិខិតប្រៃសណីយ៍ អ៊ីម៉ែល ទូរស័ព្ទ ទូរលេខ ឬទូរសារ នោះធនាគារអាចអនុវត្តដោយផ្អែកលើការណែនាំទាំងនោះតែម្តង ប្រសិនបើបុគ្គលិករបស់ធនាគារដែលទទួលបានការណែនាំនោះ ជឿជាក់ថាពិតជាបានទទួលពីអ្នកខ្ចី ឬ ក្នុងនាមអ្នកខ្ចី ហើយមានការអនុញ្ញាតត្រឹមត្រូវ និងពេញលេញ ទោះបីជាការណែនាំនោះមិនត្រូវបានអនុញ្ញាតត្រឹមត្រូវ និងពេញលេញ ហើយទោះបីជា ពេលក្រោយមកទៀត មានការបញ្ជាក់ពីអ្នកខ្ចីថាមានលក្ខណៈខុសគ្នាពីការណែនាំនោះក៏ដោយ។

12.3 អ្នកខ្ចី យល់ព្រម និងទទួលសងនូវសំណងការខូចខាតជូនធនាគារ និងធានាចេញមុខទទួលខុសត្រូវជំនួសឱ្យធនាគារចំពោះការខាតបង់ ការប្តឹងទាមទារ បណ្តឹង នីតិវិធីតុលាការ ការទាមទារ ការខូចខាត សោហ៊ុយ និងការចំណាយផ្សេងៗ (រួមបញ្ចូលទាំងកម្រៃសេវាកម្មផ្នែកច្បាប់ និងការចំណាយនានា) ដែលកើតមានឡើង ឬទទួលរងដោយផ្ទាល់ ឬដោយប្រយោលពីសំណាក់ធនាគារ តាមគ្រប់រូបភាព និងគ្រប់មធ្យោបាយដែលកើតឡើង ដោយសារតែការណ៍ដែលធនាគារប្រតិបត្តិតាម និងចាត់វិធានការទៅតាមការណែនាំរបស់អ្នកខ្ចី ដែលធ្វើតាមលិខិតប្រៃសណីយ៍ អ៊ីម៉ែល ទូរស័ព្ទ ទូរលេខ ឬទូរសារ ។

## 13. ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និង ហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

ធនាគារ អាចពន្យារពេល បង្អាក ឬបដិសេធការធ្វើប្រតិបត្តិការណាមួយ ប្រសិនបើធនាគារសង្ស័យ ឬមានហេតុផលសមរម្យជាមូលដ្ឋានក្នុងការសង្ស័យថា

(i) ប្រតិបត្តិការនោះ អាចបំពានច្បាប់ ឬបទប្បញ្ញត្តិជាធរមាន

(ii) ប្រតិបត្តិការនោះមានការពាក់ព័ន្ធ ឬអាចពាក់ព័ន្ធទៅនឹងបុគ្គលណាម្នាក់ (រូបវន្តបុគ្គល ក្រុមហ៊ុន ឬក៏រដ្ឋាភិបាល) ដែលជាប់ទណ្ឌកម្ម ឬដែលពាក់ព័ន្ធដោយផ្ទាល់ ឬប្រយោលជាមួយបុគ្គលណាមួយដែលជាប់ទណ្ឌកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្មដែលបានដាក់ដោយសហរដ្ឋអាមេរិក អង្គការសហប្រជាជាតិ សហគមន៍អឺរ៉ុប អង្គកា ដែលរួមដោយប្រទេសមហាអំណាច ស្ថាប័នផ្លូវការ ឬប្រទេសណាមួយ

(iii) ប្រតិបត្តិការអាចមានពាក់ព័ន្ធដោយផ្ទាល់ ឬប្រយោលជាមួយផល ឬប្រតិបត្តិការ ត្រូវបានអនុវត្តក្នុងគោលបំណងប្រព្រឹត្តនូវសកម្មភាពខុសច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា ឬប្រទេសណាមួយ ហើយអ្នកខ្ចីទទួលស្គាល់ថា ធនាគារ មិនទទួលខុសត្រូវចំពោះបញ្ហាដែលកើតមានឡើងឡើយ។

អ្នកខ្ចី ត្រូវផ្តល់នូវរាល់ព័ត៌មានទាំងអស់ដែលសមស្របទៅឱ្យធនាគារ តាមការទាមទាររបស់ធនាគារ ដើម្បី (១)

គ្រប់គ្រងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម ឬ ទណ្ឌកម្មសេដ្ឋកិច្ចនិងពាណិជ្ជកម្ម ឬ (២) គោរពតាមច្បាប់ ឬ បទប្បញ្ញត្តិណាមួយ ឬ (៣) គោរពតាមការណែនាំ សំណើ ឬលក្ខខណ្ឌតម្រូវ (ទោះបីជាមាន ឬគ្មានអានុភាពផ្លូវច្បាប់ក៏ដោយ) ដែលដាក់ចេញដោយរដ្ឋាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត។ អ្នកខ្ចី អះអាងចំពោះធនាគារថា ការធ្វើប្រតិបត្តិការណាមួយដោយធនាគារ តាមរយៈការនាំរបស់អ្នកខ្ចី នឹងមិនបំពានច្បាប់ ឬបទប្បញ្ញត្តិរបស់ប្រទេសណាមួយឡើយ។

## 14. ច្បាប់គ្រប់គ្រង ការដោះស្រាយវិវាទ និងការកែប្រែខចែងនិងលក្ខខណ្ឌនេះ

14.1 ខចែង និងលក្ខខណ្ឌនេះ និងលិខិតផ្តល់ឥណទាន ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងការបកស្រាយស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ហើយរាល់ជម្លោះដែលកើតមានឡើង ឬមានទំនាក់ទំនងនឹង ខចែង និងលក្ខខណ្ឌនេះ និង/ឬ កិច្ចព្រមព្រៀងឥណទាននេះ ត្រូវប្តឹងទៅកាន់តុលាការកម្ពុជាដើម្បីកាត់សេចក្តី ។

14.2 អ្នកខ្ចី យល់ព្រមថា នៅគ្រប់ពេលវេលា ធនាគារមានឆន្ទានុសិទ្ធិក្នុងការកែប្រែ បន្ថែម កែប្រែឡើងវិញ ឬផ្លាស់ប្តូរប្រការណាមួយដែលមានចែងនៅក្នុង ខចែង និងលក្ខខណ្ឌនេះ ហើយអត្រាការប្រាក់ កម្រៃសេវា និងសោហ៊ុយផ្សេងៗ ដែលទាក់ទងទៅនឹងកម្ចីនេះ ដោយគ្រាន់តែជូនដំណឹងឱ្យទៅអ្នកខ្ចី តាមមធ្យោបាយទំនាក់ទំនងដែលបានឯកភាពក្រោម ខចែង និងលក្ខខណ្ឌនេះ ហើយការកែប្រែទាំងនេះ ត្រូវមានអានុភាព ក្នុងរយៈពេល 30 ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីការផ្លាស់ប្តូរនោះ ហើយការផ្លាស់ប្តូរនេះត្រូវចងភ្ជាប់ជាកាតព្វកិច្ចចំពោះអ្នកខ្ចី ដោយពុំចាំបាច់មានការព្រមព្រៀងពីអ្នកខ្ចីឡើយ។

14.3 បន្ថែមលើមធ្យោបាយទំនាក់ទំនងដូចដែលមានចែងនៅក្នុងប្រការ ១១ និងប្រការ ១២ នៃ ខចែង និងលក្ខខណ្ឌនេះ ធនាគារ អាចជូនដំណឹងទៅឱ្យអ្នកខ្ចីតាមរយៈគេហទំព័រ តាមការជូនដំណឹងដែលមានបង្ហាញនូវសាខារបស់ធនាគារបណ្តាញសង្គមផ្លូវការរបស់ធនាគារ ការផ្សាយពាណិជ្ជកម្ម និងការជូនដំណឹងតាមរយៈសារព័ត៌មានជាតិធំៗប្រចាំថ្ងៃ។ ការជូនដំណឹងនេះ ត្រូវបានចាត់ទុកថាអ្នកខ្ចីបានទទួល បន្ទាប់ពីការផ្សព្វផ្សាយតាមមធ្យោបាយទាំងនោះ។

## 15. បញ្ញត្តិទូទៅ

15.1 ប្រសិនបើប្រការណាមួយនៃ ខចែង និងលក្ខខណ្ឌនេះ ឬផ្នែកណាមួយនៃប្រការខាងលើ ត្រូវបានចាត់ទុកជាមោឃៈ ឬមិនអាចអនុវត្តបាន ដោយអាជ្ញាធរមានសមត្ថកិច្ច នោះផ្នែកផ្សេងទៀតនៅតែមានសុពលភាពអនុវត្តដដែល។

15.2 ការយឺតយ៉ាវ ឬការខកខានដោយធនាគារក្នុងការអនុវត្ត ឬការឱ្យអនុវត្ត (ទាំងស្រុង ឬដោយផ្នែក) នូវសិទ្ធិ ឬវិធានសង្គ្រោះណាមួយក្រោមកិច្ចព្រមព្រៀងឥណទាននេះ នឹងមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ ឬវិធានសង្គ្រោះដែលធនាគារអាចមាននោះឡើយ ហើយការយឺតយ៉ាវ ឬ ការខកខាននេះ ក៏មិនត្រូវចាត់ទុកជាការលះបង់សិទ្ធិនោះដែរ។

15.3 ការលើកលែងដោយធនាគារចំពោះការបំពាន ឬមិនគោរពប្រការណាមួយនៃ ខចែង និងលក្ខខណ្ឌនេះ មិនត្រូវចាត់ទុកជាការលើកលែងចំពោះការបំពាន ឬការមិនគោរពប្រការស្រដៀងគ្នា ឬប្រការដ៏ទៀតនៃ ខចែង និងលក្ខខណ្ឌនេះឡើយ។ ការមិនទទួលអត្ថប្រយោជន៍ពីសិទ្ធិ ឬការមិនអនុវត្តសិទ្ធិណាមួយដែលផ្តល់ឱ្យដោយធនាគារ មិនត្រូវចាត់ទុកថាជាការលើកលែង ឬជាការឱ្យអ្នកខ្ចីរួចផុតពីការអនុវត្តតាម ឬបំពេញ

កាតព្វកិច្ចរបស់អ្នកខ្ចី ដូចមានចែងនៅក្នុង ខ និងលក្ខខណ្ឌនេះឡើយ។

15.4 ខចែង និងលក្ខខណ្ឌនេះត្រូវបានធ្វើឡើងជាភាសាខ្មែរ និងភាសាអង់គ្លេស ប្រសិនបើមានភាពមិនស៊ីសង្វាក់គ្នា នោះភាសាខ្មែរត្រូវមានឧត្តមានុភាព។

# អាសយដ្ឋានរបស់សាខាធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់

### ការិយាល័យកណ្តាល

អគារ Royal Railway លេខ១០ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

### សាខាក្រមួនស

អគារ Royal Railway លេខ១០ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

### សាខាវិមានឯករាជ្យ

អគារលេខ ១០០ វិថីព្រះសីហនុ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

### សាខាផ្សារអូឡាំពិក

អគារលេខ ៣៥៩ ៣៦១ និង ៣៦៣ វិថីព្រះសីហនុ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ

### សាខាទួលគោក

ផ្ទះលេខ៩៥សេ មហាវិថីគីមអ៊ិលស៊ុង (២៨៩) សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

### សាខាមាត់ទន្លេ

ផ្ទះលេខ២៦៥ និង ២៦៧ អឺ០ វិថីព្រះស៊ីសុវត្ថិ សង្កាត់ផ្សារកណ្តាលទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

### សាខាទឹកថ្លា

ផ្ទះលេខ១អឺ០ អឺ១ ផ្លូវលេខ១១០អា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

### សាខាពេទ្យលោកសង្ឃ

ផ្ទះលេខ១អា និង ១បេ អឺ០ អឺ១ អឺ២ ផ្លូវលេខ២៧១ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

### សាខាផ្សារដើមថ្កូវ

ផ្ទះលេខ៦១៦ អាបេ អឺ០ អឺ១ អឺ២ ផ្លូវលេខ២៧១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ

### សាខាស្ទឹងមានជ័យ

ផ្ទះលេខ២៣ និង ២៥ អឺ០ អឺ១ អឺ២ ផ្លូវលេខ២១៧ ភូមិដំណាក់ធំ ១ សង្កាត់ស្ទឹងមានជ័យ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

### សាខាចោមចៅ

អគារលេខ១បេ ២បេ ៣បេ ផ្លូវជាតិលេខ៤ ភូមិថ្នល់បំបែក សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

### សាខាខេត្តបាត់ដំបង

ផ្ទះលេខ០២ ០៤ និង០៦ ផ្លូវលេខ១១៣ ភូមិ២០ឧសភា សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

### សាខាខេត្តកំពង់ចាម

ភូមិទី១២ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម

### សាខាខេត្តសៀមរាប

អគារលេខ៥៦៦ ៥៦៨ ៥៧០ ផ្លូវទេពវង្ស ភូមិមណ្ឌល១ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប

### សាខាខេត្តព្រះសីហនុ

ផ្ទះលេខ២១៩ ផ្លូវឯករាជ្យ ភូមិ២ សង្កាត់២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

### សាខាសែនសុខ

អគារលេខ ស៊ី៤ #០១ ប៊ី#០២ ប៊ី#03 និង ឌី២#04 ផ្លូវលេខ១០០៣ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ

### សាខាច្បារអំពៅ

ផ្ទះលេខ ៧២ អេ ប៊ី ស៊ី ឌី ផ្លូវជាតិលេខ ១ ភូមិកោះនរា សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

### សាខាជ្រោយចង្វារ

ផ្ទះលេខ អេហ្វ០៥ ផ្លូវជាតិលេខ ៦អា ភូមិខ្ទរ សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

### ព័ត៌មានទំនាក់ទំនង

លេខទូរសព្ទ : +855 23 999 000 (24/7)
អ៊ីម៉ែល : ccc@jtrustroyal.com
គេហទំព័រ : www.jtrustroyal.com